# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍

## របៀបវារៈទី IV: ការគាំទ្រដល់សូចនាករឃ្លាំមើលរួមគ្នាឆ្នាំ២០១០

**ថ្លែងដោយលោកស្រី Elena Tischenko, នាយក UNDP ប្រចាំនៅកម្ពុជា**

**តំណាងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី៣**

ភ្នំពេញ ថ្ងៃទី 3 ខែ មិថុនា ឆ្នាំ 2010

*សូមគោរព*

*- ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ជាទីគោរពរាប់អាន!*

ក្នុងនាមដៃគូអភិវឌ្ឍន៍នានា ខ្ញុំមានសេចក្តីរីករាយ ក្នុងការបង្ហាញជូននូវ សូចនាករឃ្លាំមើលរួមគ្នា (JMIs) ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

សូចនាករ JMIs មាននាទីមិនត្រឹមតែសម្រាប់ការសម្រេចបានរួមគ្នានូវ NSDP និង វិស័យអាទិភាពនានាប៉ុណ្ណោះទេ ប៉ុន្តែសូចនាករទាំងនេះ ក៏បានរួមចំណែកក្នុងការពង្រឹងភាពជាដៃគូ រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ផងដែរ ។ អាស្រ័យហេតុនេះ យើងមានសេចក្តីរីករាយណាស់ ដែលអាចគាំទ្រដល់កម្រងសូចនាករឃ្លាំមើលរួមគ្នាទាំងនេះ សម្រាប់រយៈពេលរហូតដល់ចុងឆ្នាំ 2011 ។

### ការរីកចម្រើននៅក្នុងការអនុវត្តសូចនាករ JMIs ឆ្នាំ 2008

ក្នុងនាមដៃគូអភិវឌ្ឍន៍ទាំងអស់ ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីធ្វើការឆ្លុះបញ្ចាំងដោយត្រួសៗអំពីការរីកចម្រើន និងដំណើរការនៃ JMI កន្លងមក ដែលមានបំណងរួមចំណែកក្នុងការអនុវត្តដោយជោគជ័យ នូវសូចនាកររួមគ្នាសម្រាប់ឆ្នាំ 2010-2011 ។ ទោះបីឆ្នាំ 2008 និង 2009 បានជួបប្រទះនូវការប្រឈមមួយចំនួនក៏ដោយ ជារួម របាយការណ៍អំពីការរីកចម្រើននៃ JMI និងរបាយការណ៍អំពីប្រសិទ្ធិភាពជំនួយនៅឆ្នាំ 2010 បង្ហាញពីការរីកចម្រើនជាវិជ្ជមាន ឆ្ពោះទៅម្រេចចំណុចគោលដៅ JMI សម្រាប់ឆ្នាំ 2008 ។ ខ្ញុំសូមធ្វើការកត់សំគាល់អំពីសមិទ្ធផលសំខាន់ៗទាំងនេះដូចតទៅ :

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានធ្វើបច្ចុប្បន្នភាព និងបន្តសុពលភាព (JMI 1)
- សម្រេចបាននូវការរីកចម្រើន នៅក្នុងការជម្រុញអត្រានៃការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា (JMI 3); និង
- ការដាក់ជូន និងការអនុម័តឯកភាពលើក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីប្រឆាំងអំពើពុករលួយ (JMI 17) ។

របាយការណ៍នានា ក៏គូសបញ្ជាក់ផងដែរ អំពីវិស័យមួយចំនួន ដែលកិច្ចប្រឹងប្រែងក្នុងការសម្រេចចំណុចគោលដៅរួមគ្នាបានប្រឈមនឹងឧបសគ្គ។ របាយការណ៍របស់រដ្ឋាភិបាលស្តីពីប្រសិទ្ធិភាពជំនួយ បានបង្ហាញថា នៅក្នុងវិស័យជាច្រើន កិច្ចប្រឹងប្រែងត្រូវបានធ្វើឡើង ប៉ុន្តែនៅមានវិធីដែលគួរតែអាចកែលម្អបាន មុននឹងអាចសម្រេចបានទាំងស្រុងនូវការរីកចម្រើននានា។ ជាក់ស្តែង កិច្ចប្រឹងប្រែងនានា នៅតែបន្តពង្រឹងវិស័យមួយចំនួនថែមទៀត មានដូចជាវិស័យ ព្រៃឈើ កំណែទម្រង់ប្រព័ន្ធតុលាការ ដីធ្លី សកម្មភាពដោះមីន និង ការថែទាំផ្លូវថ្នល់។

ដោយសារតែភាពស្មុគស្មាញនៃភាពជាដៃគូពហុស្ថាប័ននៅតាមវិស័យនានា យើងមើលឃើញថា ការប្រឈមនៅក្នុងការអនុវត្ត នៅតែបន្តមាន ទាំងសម្រាប់ដៃគូអភិវឌ្ឍន៍ និង រដ្ឋាភិបាល។ បញ្ហានានាដែលបានលើកឡើងរួមមាន ភាពនៅមានកម្រិតក្នុងកិច្ចការសម្របសម្រួលអន្តរក្រសួង មហិច្ឆិតាខ្ពស់ពេលក្នុងការកំណត់ចំណុចគោលដៅ ភាពខ្សោយនៃព័ត៌មានមូលដ្ឋាន កម្រិតទាបនៃការបន្សីុគ្នា និង សុខដុម្មនីយកម្មចំណោមដៃគូអភិវឌ្ឍន៍ ធនធានមិនគ្រប់គ្រាន់ និង កង្វះសមត្ថភាព។

- យើងសូមស្វាគមន៍យោបល់នានា ពីរាជរដ្ឋាភិបាលកម្ពុជា អំពីរបៀប ដែលកិច្ចប្រឹងប្រែងនានា ដើម្បីពង្រឹងការគ្រប់គ្រងផ្អែកលើលទ្ធផល ហើយផ្តោតលើសមិទ្ធផល និង ភាពជាដៃគូ អាចកែលម្អវិស័យនានា ដែលការរីកចម្រើន នៅតែមានកម្រិតនៅឡើយ។
- ដើម្បីពង្រឹងភាពជាដៃគូជាមួយរដ្ឋាភិបាល យើងសូមស្វាគមន៍ឱ្យមានជំហ៊ានបន្តនៃគំនិតផ្តួចផ្តើមស្តីពី "ការធ្វើឱ្យភាពជាដៃគូនៅកម្ពុជាមានប្រសិទ្ធិភាព" និង រង់ចាំទទួលការណែនាំពីរដ្ឋាភិបាល អំពីរបៀបដែលដៃគូអភិវឌ្ឍន៍អាចធ្វើគាំទ្របានល្អប្រសើរបំផុត ដល់ការអនុវត្តកិច្ចការនេះ។

## ស្វាគមន៍ចំពោះការយកចិត្តទុកដាក់លើការគ្រប់គ្រងផ្អែកតលើលទ្ធផល

យើងសូមស្វាគមន៍ចំពោះកំណើនការយកចិត្តទុកដាក់ចំពោះ JMIs និងកោតសរសើរចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការធានាថា សូចនាករទាំងនេះ មានចំណងទាក់ទងជាមួយការសម្រេចបានលទ្ធផលនៃការអភិវឌ្ឍ នៅគ្រប់វិស័យទាំងអស់ និង វិស័យនានានៃកំណែទម្រង់។ អភិក្រមដែលបានប្រកាន់យកនៅក្នុងការបង្កើតសូចនាករ JMIs ថ្មីៗទាំងនេះ នឹងជួយពង្រឹង ចំណងទាក់ទងរវាង "ការគ្រប់គ្រងដើម្បីលទ្ធផលនៃការអភិវឌ្ឍ" និងគោលការណ៍នៃភាពជាដៃគូរបស់យើងស្តីពី "គណនេយ្យភាព រួមគ្នា"។ យើងពិតជាត្រូវបង្កើនការយកចិត្តទុកដាក់ ចំពោះលទ្ធផលនៃការងាររបស់យើង ហើយយើងទទួលស្គាល់ថា មានតែតាមរយៈការធ្វើការរួមគ្នា ក្រោមភាពជាដៃគូ ដែលពឹងផ្អែកលើគណនេយ្យភាពទៅវិញទៅមកប៉ុណ្ណោះ ទើបយើងអាចរំពឹងថានឹងសម្រេចបាន តាមមហិច្ឆិតាដែលយើងប្រាថ្នាចង់បាន។

មានការរីកចម្រើនជារួមដែលគួរឱ្យកោតសរសើរអំពីវត្តមាន និងគុណភាពនៃ JMIs ប៉ុន្តែទន្ទឹមនឹងនេះ លទ្ធផលនៃ JMI មានភាពខុសគ្នាយ៉ាងខ្លាំង លើកម្រិតមហិច្ឆិតា។ ប្រការសំខាន់គឺ CRDC/CDC នៅតែបន្តផ្តល់ការដឹកនាំ និងការណែនាំដល់ TWGs ដើម្បីធានាឱ្យមានសង្គតិភាពសម្រាប់ក្របខ័ណ្ឌ និងការតាមឃ្លាំមើល JMIs។

លើសពីនេះ ការបណ្តុះបណ្តាលអំពី ការគ្រប់គ្រងផ្អែកលើលទ្ធផល ដែលគាំទ្រដោយ CDC ដល់ក្រុមការងារបច្ចេកទេស មានប្រយោជន៍ជាខ្លាំង និង ផ្តល់ជាវេទិកាសម្រាប់ការគាំទ្រជាបន្ថែម ក្នុងការចាត់ចែង និង អនុវត្តគោលការណ៍នានា ព្រមទាំងបច្ចេកទេសនៃ ការគ្រប់គ្រងផ្អែកលើលទ្ធផល នៅក្នុងក្រុមការងារបច្ចេកទេស ។

- ដៃគូអភិវឌ្ឍន៍ លើកទឹកចិត្តឱ្យមានការប្រើប្រាស់អភិក្រមនៃការគ្រប់គ្រងការអភិវឌ្ឍដើម្បីលទ្ធផល ដោយផ្តោតលើការងារនៅគ្រប់វិស័យ ប៉ុន្តែមិនត្រឹមតែលើវិស័យដែលមានចែងនៅក្នុង JMIs ឡើយ ។ យើងស្វាគមន៍ចំពោះការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា អំពីរបៀបបន្តកិច្ចប្រឹងប្រែងដើម្បីពង្រឹង ការគ្រប់គ្រងផ្អែកលើលទ្ធផល ។

**ពិនិត្យមើលយន្តការឃ្លាំមើល ដើម្បីពង្រឹងការអនុវត្ត**

តាមរយៈការពង្រឹង ការអនុវត្តនិងការឃ្លាំមើល JMIs, យើងអាចកែលម្អប្រសិទ្ធិផល ប្រសិទ្ធិភាព និង តម្លាភាព នៃកិច្ចប្រឹងប្រែងរួមគ្នារបស់យើង ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ។ ដៃគូអភិវឌ្ឍន៍ ឯកភាពជាមួយសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបញ្ជាក់អំពីភាពចាំបាច់ឱ្យយើងធ្វើការជាមួយគ្នា ដើម្បីពង្រឹងការឃ្លាំមើលរួមគ្នា មិនត្រឹមតែលើ JMIs ប៉ុណ្ណោះទេ ប៉ុន្តែ លើកិច្ចសហប្រតិបត្តិការរបស់យើងជាមួយរបស់រដ្ឋាភិបាលផងដែរ ។

យើងឯកភាពជាមួយរដ្ឋាភិបាល ដែលអះអាងថា មានឱកាសសម្រាប់កែលម្អរចនាសម្ព័ន្ធ និង បរិធាននៃការសម្របសម្រួលជំនួយសព្វថ្ងៃនេះ ។ មានវិស័យជាអាទិភាពនៅក្នុង NSDP ដែល i) មានការពាក់ព័ន្ធជាមួយក្រសួង និង/ ឬ ទីភ្នាក់ងារជាច្រើន ឬ ii) មិនស្របទៅនឹង វិស័យ ឬ ចំណុចផ្តោតយកចិត្តទុកដាក់ ដែលមានស្រាប់របស់ក្រុមការងារបច្ចេកទេស ។ នេះជាបញ្ហាកើតមានយូរមកហើយ ដែលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានលើកឡើងនៅក្នុងអំឡុងនៃការពិនិត្យរបស់ GDCC និង TWGs នាឆ្នាំ 2006 និង ពិភាក្សានៅក្នុង CDCF លើកទី 2 ។ ជាលទ្ធផល វិស័យនានា ដូចជា ឧស្សាហកម្មនិស្សារណកម្ម ដីសម្បទាន-សេដ្ឋកិច្ច កិច្ចការពារដីធ្លីរបស់ជនជាតិដើមភាគតិចមុនពេលចុះបញ្ជី និង ជនពិការ មិនមានចែង ឬ គាំទ្រប្រកបដោយប្រសិទ្ធិភាពឡើយ នៅក្នុងរចនាសម្ព័ន្ធសព្វថ្ងៃនេះ ។

បញ្ហាទាំងនេះ ដែលមិនមានឆ្លុះបញ្ចាំងនៅក្នុងការឃ្លាំមើលជាបន្តបន្ទាប់នៃ JMIs ពុំមានរចនាសម្ព័ន្ធណាមួយ ដើម្បីធានាឱ្យមានការបន្តផ្តោតយកចិត្តទុកដាក់ និង កិច្ចប្រឹងប្រែងលើការសម្រេចបាននូវលទ្ធផលនៃការអភិវឌ្ឍឡើយ ។ ការពិភាក្សាប្រកបដោយការស្ថាបនា នៅក្នុងវិស័យទាំងនេះខ្លះៗ បានសម្រេចដោយជោគជ័យរួចទៅហើយ (ដូចជា ការពិភាក្សារវាង អាជ្ញាធរប្រេងកាតជាតិកម្ពុជា និង ក្រុមការងារមិនផ្លូវការស្តីពីប្រេងនិងឧស្ម័ន) ។ វិស័យមួយចំនួន បានទទួលការគាំទ្រយ៉ាងមានប្រសិទ្ធិភាព តាមរយៈការប្តេជ្ញា ដែលបានធ្វើឡើងនៅក្នុង CDCF នាឆ្នាំ 2008 (ដូចជា លើការពង្រឹងកិច្ចការពារសង្គម) ។ វិស័យផ្សេងទៀត បានទទួលនូវការគាំទ្រតិចតួចជាងចំពោះការឃ្លាំមើល (ដូចជា សព្វថ្ងៃនេះ នៅក្នុងរចនាសម្ព័ន្ធនៃ TWG ពុំមានលេខាធិការដ្ឋាន ដើម្បីឱ្យមានការបន្តពិភាក្សា អំពីដីសម្បទានសេដ្ឋកិច្ចឡើយ) ។

នេះជាតួនាទីរបស់ GDCC ក្នុងការឯកភាព និងតាមមើលការរីកចម្រើននៃ JMIs និងលើកឡើងនូវបញ្ហានានា (នៅក្នុង JMIs ឬ វិស័យផ្សេងទៀត) ដែលមិនអាចដោះស្រាយបាននៅកម្រិតបច្ចេកទេស ។ ទោះជាយ៉ាងណាក៏ដោយ រចនាសម្ព័ន្ធ GDCC

សព្វថ្ងៃនេះ មិនអនុញ្ញាតឱ្យមានយន្តការឃ្លាំមើលរួមគ្នាទូលំទូលាយ ដើម្បីតាមមើលការរីកចម្រើន និងធ្វើការសម្រេចនានា លើចំណាត់ការសំខាន់ៗឡើយ។ រាជរដ្ឋាភិបាលកម្ពុជា ទទួលបាននូវការធានាអំពីភាពជាដៃគូប្រកបដោយការស្វាគមន៍ ជាមួយដៃគូអភិវឌ្ឍន៍ ក្នុងការធ្វើឱ្យ GDCC ក្លាយជាយន្តការដ៏មានប្រសិទ្ធិភាពមួយ សម្រាប់គាំទ្រការអនុវត្ត និងការឃ្លាំមើល JMI ។

- យើងសូមស្វាគមន៍ចំពោះឱកាស ដើម្បីស្វែងរកវិធីនានា ក្នុងការពង្រឹងក្របខ័ណ្ឌនៃភាពជាដៃគូ សម្រាប់គោលនយោបាយអាទិភាពនៃ NSDP ដែលសព្វថ្ងៃនេះស្ថិតក្រោមយន្តការ TWG-JMI ។ ការសម្រេចទាំងឡាយ ដែលបានធ្វើឡើងទាក់ទងនឹងបញ្ហានានា ដូចជានៅក្នុង CDCF ឆ្នាំ 2008 បានជួយគាំទ្រដល់ការឃ្លាំមើល និង ការរីកចម្រើនលើសូចនាករមួយចំនួន។ ការតាមឃ្លាំមើល លើសេចក្តីសម្រេចបន្តតាមដានរបស់ CDCF ក្នុងឆ្នាំ 2010 អាចនឹងទទួលបានពង្រឹងបន្ថែម ដើម្បីធ្វើឱ្យមានកំនើនការគាំទ្រ។ ជំហ៊ានដែលមានប្រសិទ្ធិភាពសម្រាប់ពេលខាងមុខ អាចជាកិច្ចការខ្លីមួយ ដើម្បីពិនិត្យមើលដំណើរការ ពិភាក្សាដែលមានស្រាប់ និង ការរីកចម្រើន លើបញ្ហានានាដែលបានធ្វើអត្តសញ្ញាណ និងឯកភាពគ្នា លើរបៀបការឃ្លាំមើលត្រូវបានពង្រឹង ដោយមានសេចក្តីរាយការណ៍អំពីការរីកចម្រើននៅក្នុង CDCF លើកក្រោយ និងតាមឃ្លាំមើលដោយ GDCCs។ គោលការណ៍សំខាន់មួយ គឺត្រូវធ្វើឱ្យប្រាកដថា ការតាមឃ្លាំមើលសេចក្តីសម្រេចនានានៅក្នុង CDCF និង សកម្មភាពជាបន្ត លើបញ្ហាទាំងនោះ ជាការបំពេញបន្ថែមចំពោះ JMIs និងមិនមែនជាឧបសគ្គចំពោះ JMIs ឡើយ។ ដៃគូអភិវឌ្ឍន៍ សូមស្វាគមន៍ចំពោះការណែនាំរបស់រដ្ឋាភិបាល នូវរបៀបពង្រឹងការឃ្លាំមើល សម្រាប់គាំទ្រដល់ការរីកចម្រើន នៃគោលនយោបាយជាអាទិភាព ដែលមិនស្ថិតនៅក្នុងយន្តការ TWG-JMI ។
- យើងសូមស្វាគមន៍ចំពោះឱកាស ដើម្បីស្វែងរកវិធីនានា សម្រាប់ពង្រឹងការយកចិត្តទុកដាក់នៅកម្រិតខ្ពស់នៃ GDCC ដើម្បីដោះស្រាយបញ្ហានានា ដែលមិនស្ថិតនៅក្នុងប៉ារ៉ាម៉ែត្រនៃ JMIs នីមួយៗ ទន្ទឹមគ្នានឹងការពង្រឹងផងដែរ នូវសមត្ថភាពរបស់ខ្លួន ក្នុងផ្តល់យន្តការរឹងមាំ សម្រាប់ការឃ្លាំមើល JMIs ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!*

ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីអះអាងឡើងវិញនូវការគាំទ្ររបស់យើងចំពោះ JMIs ឆ្នាំ 2010 ។

ទីបំផុត ខ្ញុំសូមកោតសរសើរចំពោះតួនាទីរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ក្នុងតួនាទីគាំទ្រដល់ JMIs នៅក្នុង GDCC, និងសូមថ្លែងអំណរគុណចំពោះឯកឧត្តម **ឈៀង យ៉ាន់ណារ៉ា** មកពី CDC ក៏ដូចជា ប្រធាន TWG ទាំងអស់ ដែលបានចរចារលើ JMIs និងដែលមានការប្តេជ្ញា ដើម្បីពង្រឹងឥទ្ធិពលនៃការងាររបស់យើង។

យើងសូមប្តេជ្ញា ធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាឱ្យមានការអនុវត្តប្រកបដោយជោគជ័យ និងការតាមឃ្លាំមើលប្រកបដោយប្រសិទ្ធិភាព។

សូមអរគុណ!